**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១៧-១៧៣-ឆ.ផ.ស

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា(LPCO)
## លើកទី ៥

យោងតាមសេចក្តីជូនដំណឹងលេខ ធ១.០១៦.០៥៤.ពិសេស ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបអំពីការដេញថ្លៃក្នុងប្រតិបត្តិការ LPCO ដូចតទៅ៖

| | |
|---|---|
| - កាលបរិច្ឆេទដេញថ្លៃ | : ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ |
| - ពេលវេលាដាក់ដេញថ្លៃ | : ពីម៉ោង៨:០០នាទីព្រឹក ដល់ ១២:០០នាទីថ្ងៃត្រង់ |
| - ថ្ងៃប្រសិទ្ធភាពទូទាត់ | : ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ |
| - កាលវសាន | : ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ |
| - ទឹកប្រាក់ដាក់ឲ្យដេញថ្លៃ | : ៤០.០០០.០០០.០០០ (សែសិបប៊ីលាន) រៀល |
| - ទឹកប្រាក់ដេញថ្លៃអប្បបរមា/គ្រឹះស្ថាន | : ២០០.០០០.០០០ (ពីររយលាន)រៀល |
| - ទឹកប្រាក់ដេញថ្លៃអតិបរមា/គ្រឹះស្ថាន | : ៨.០០០.០០០.០០០ (ប្រាំបីប៊ីលាន)រៀល |
| - អត្រាការប្រាក់ដេញថ្លៃអប្បបរមា | : ៣% |
| - នីតិវិធីដេញថ្លៃ | : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និង អត្រាការប្រាក់ដេញថ្លៃជាភាគរយ(ពីរខ្ទង់ក្រោយក្បៀស) |
| - វត្ថុធានា | : NCD(ជារៀលឬដុល្លារ) ត្រូវមានឥណប្រតិទាន យ៉ាងតិចបីខែ។ NCD ជាដុល្លារត្រូវកំណត់ haircut ៥% នៃទឹកប្រាក់ដែលដេញថ្លៃបាន។ |

ពាក្យសុំដេញថ្លៃត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា តាមរយៈសារអេឡិចត្រូនិក bod_lpco@nbc.org.kh។ ក្នុងករណីដែលសារអេឡិចត្រូនិកមិនដំណើរការ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើមកនាយកដ្ឋានប្រតិបត្តិការ ឲ្យបានមុនម៉ោង ១២:០០ នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលទទួលបានជោគជ័យត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មការរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការLPCO ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងមកនាយកដ្ឋានប្រតិបត្តិការ
តាមរយៈលេខទូរស័ព្ទ : ០១២ ៩៦៩ ៦៤៤ / ០៧៧ ៩៦១ ៩៩១